# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ អគតិធម៌៤ ។

www.hoksavann.org

ថ្ងៃទី១១ សីហា ២០១១



អគតិធម៌ ប្រែថា ធម៌លំអៀងមាន៤យ៉ាងគឺ ៖ ឆន្ទាគតិ លំអៀងព្រោះស្រឡាញ់, ទោសាគតិ លំអៀងព្រោះស្អប់, ភយាគតិ លំអៀងព្រោះខ្លាច, មោហាគតិ លំអៀងព្រោះល្ងង់ ។ អគតិទាំងបួននេះជាអំពើអយុត្តិធម៌ ប្រែថាធម៌ពុំត្រឹមត្រូវ ជាគន្លងនៃអំពើបាប ។

ពាក្យថា ឆន្ទាគតិ លំអៀងព្រោះស្រឡាញ់ សំរេចសេចក្តីអ្វីមួយដោយការកាន់ជើង បើចៅក្រមកាត់សេចក្តីឲ្យអ្នកដែលខ្លួនកាន់ជើងនោះឈ្នះ ព្រោះហេតុតែសេចក្តីស្រឡាញ់ ទោះអ្នកនោះមានកំហុសក៏ដោយ ។

ទោសាគតិ លំអៀងព្រោះស្អប់ បើទោះបីអ្នកដែលខ្លួនស្អប់នោះធ្វើត្រូវក៏ដោយ ឲ្យតែខុសឲ្យចាញ់ដែរព្រោះហេតុស្អប់ ។

ភយាគតិ លំអៀងដោយភ័យខ្លាច ពុំហ៊ានសំរេចឲ្យខុសដល់អ្នកដែលមានកំហុសដែលជាអ្នកមានអំណាចបុណ្យស័ក្តិ មានទ្រព្យសម្បត្តិច្រើន ដោយខ្លាចអ្នកនោះធ្វើសេចក្តីអន្តរាយសងសឹកដល់ខ្លួនវិញ នេះលំអៀងព្រោះភ័យខ្លាច ។

មោហាគតិ លំអៀងព្រោះល្ងង់ឬពុំដឹងការពិត គឺអ្នកមានវិជ្ជា មានបញ្ញាទន់ខ្សោយ ឬជាអ្នកគ្មានសមត្ថភាពបានសំរេចបញ្ហាអ្វីមួយពុំត្រឹមត្រូវ គឺសំរេចទៅតាមភាពល្ងង់ខ្លៅរបស់ខ្លួន ។

អគតិធម៌ទាំងបួននេះជាធម៌អកុសលជាអំពើបាប ដែលលោកអ្នកសប្បុរសតែងវៀរចាក ជាពិសេសចៅក្រមកាត់សេចក្តីក្នុងតុលាការត្រូវតែវៀរចាកកុំឲ្យមាន ទើបការកាត់សេចក្តីមានយុត្តិធម៌ ។

ចំពោះតុលាការក្នុងប្រទេសដែលកាន់របបប្រជាធិបតេយ្យ មានអំណាចឯករាជ្យដាច់ចេញពីអំណាចនីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិគឺរដ្ឋាភិបាល ។ បានសេចក្តីថា រដ្ឋាភិបាលមាននាយករដ្ឋមន្ត្រីឬរដ្ឋមន្ត្រីទី១ជាដើម មិនអាចបញ្ជាទៅកាន់តុលាការឲ្យធ្វើតាមខ្លួនបានឡើយ ។ សូម្បីប្រធានាធិបតីឬប្រមុខរដ្ឋក៏ពុំអាចធ្វើដូច្នេះបានដែរ ផ្ទុយទៅវិញបើរដ្ឋមន្ត្រីណាធ្វើខុសច្បាប់របស់រដ្ឋ តុលាការមានសិទ្ធិជំនុំជំរះកាត់ទោសរដ្ឋមន្ត្រីនោះបានដូចជាមនុស្សធម្មតាដែរ គឺមនុស្សគ្រប់រូបទាំងប្រជាពលរដ្ឋទាំងអ្នករាជការ ត្រូវស្ថិតនៅក្រោមអំណាចច្បាប់រដ្ឋដូចគ្នា ។ បើអំណាចតុលាការមិនឯករាជ្យ ស្ថិតនៅក្រោមអំណាចរដ្ឋាភិបាល នោះតុលាការពុំអាចកាត់ទោសសមាជិករដ្ឋាភិបាលដែលប្រព្រឹត្តខុសបានឡើយ ។ ទាក់ទងនិងអ្នកមានអំណាចរំលោភច្បាប់នេះ ដូចជាប៉ូលិសឬនគរបាលមានតួនាទីរក្សាសន្តិសុខជូនប្រជាពលរដ្ឋនៅក្នុងប្រទេស ។ បើឃើញមនុស្សទាស់ទែងខ្វែងគំនិតគ្នាបំរុងប្រើអំពើហិង្សា ប៉ូលិសឬនគរបាលត្រូវធ្វើអន្តរាគមន៍បំបែកចេញ មិនត្រូវប្រើអំពើហិង្សាបែបណាមួយទៅលើប្រជាពលរដ្ឋឡើយ បើអ្នកនោះពុំបានតដៃ ។ ប៉ូលិសគួរគ្មានសិទ្ធិកាត់ទោសមនុស្សដោយខ្លួនឯងទេ សិទ្ធិនេះនៅលើតុលា-ការ ។ អគតិធម៌ទាំងបួននេះ ជាធម៌ដែលអ្នកធំអ្នកមានអំណាចត្រូវលះបង់ ហើយអនុវត្តតាមគតិធម៌ ជាពិសេសចៅក្រមកាត់សេចក្តី ។ ប្រទេសណាដែលមានចៅក្រមកាត់សេចក្តីពុំលំអៀងដោយអគតិធម៌ទាំងបួននេះ ប្រទេសនោះមានដំណើរទៅរកនីតិរដ្ឋហើយ ។ អ្នករំលោភច្បាប់អាចថយចុះ ដោយសារចៅក្រមកាត់សេចក្តីប្រកបដោយគតិយុត្តិធម៌ ផ្តន្ទាទោសតាមកំហុសចំពោះអ្នកដែលរំលោភច្បាប់ ។

ចំពោះតុលាការនៅប្រទេសកម្ពុជា បើយោងតាមរបាយការណ៍របស់អង្គការអន្តរជាតិនានា ជាពិសេសអង្គការសិទ្ធិមនុស្សបានថែងថា តុលាការនៅប្រទេសកម្ពុជានៅមានភាពទន់ខ្សោយណាស់ កាត់សេចក្តីច្រើនលំអៀងទៅរកអ្នកកាន់អំណាច និងបក្សពួកអ្នកមានទ្រព្យសម្បត្តិ ។ របាយការណ៍នេះមានភាពត្រឹមត្រូវណាស់ ព្រោះគេសង្កេតឃើញថា ប្រជាពលរដ្ឋក្រីក្រក្តីមិនដែលឈ្នះអ្នកមានអំណាចបុណ្យស័ក្តិនិងឧកញ៉ា ជាបក្សពួករបស់អ្នកមានអំណាចឡើយ ឃើញតែប្រជាពលរដ្ឋជាប់ពន្ធនាគារ និងបង់ផាកពិន័យដូចជាបញ្ហាដីធ្លីជាដើម ។ បើអ្នកកាន់អំណាចខ្មែរបច្ចុប្បន្ននៅតែយកតុលាការជាឧបករណ៍សំរាប់បំរើមហិច្ឆិតារបស់ខ្លួន ធ្វើបាបប្រជាពលរដ្ឋតទៅទៀត ឬក៏ត្រូវបញ្ឈប់អំពើអាក្រក់នេះ ។ ប្រទេសណាមួយដែលតុលាការមានភាពលំអៀង ពុំយុត្តិធម៌ ប្រទេសនោះពុំមានស្ថេរភាពក្នុងផ្លូវនយោបាយឡើយ ។៚

*  *

*